ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយការងារសហប្រតិបត្តិការអន្តរជាតិ

លេខ: ………………………………

# របាយការណ៍បូកសរុបប្រចាំខែ សីហា

## I. អំពីកម្លាំង៖

កម្លាំងសរុប៖ ០៦នាក់ (ស្រី ០២នាក់)        អវត្តមាន៖ ………………………………

## II. សកម្មភាព និងលទ្ធផលការងារ

- ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** និងលោកវរសេនីយ៍ឯក អ៊ិន មាន បានចូលរួមអមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីចូលរួមលើកិច្ចប្រជុំទី 7th Bali Process Senior Official's Meeting និង Ministerial Conference នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី។

- ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំលើ «បច្ចុប្បន្នភាពការងារយេនឌ័ររបស់ក្រសួងមហាផ្ទៃ» ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និង លោកជំទាវ ជួញ សុផៃ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ។ ក្នុងកិច្ចប្រជុំ បានលើកពីបច្ចុប្បន្នភាពការងារ ពិនិត្យលើសកម្មភាពតាមផែនការ របាយការណ៍ និងសកម្មភាពបន្ត។

- ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨ ក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការ និងក្រុមការងារបង្ការ ទប់ស្កាត់ ដែលដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** និង**លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានចូលរួមក្នុងការដោះស្រាយករណីដែលប្រជាជនមកពីខេត្តសៀមរាបស្នើឲ្យជួយដោះស្រាយលើបញ្ហាសាច់ញាតិ ដែលបានស្លាប់នៅលើទូកនេសាទនៅប្រទេសម៉ាឡេស៊ី ដើម្បីសុំអន្តរាគមន៍ ទាមទារសំណង និងយកសពឬធាតុមកស្រុកកំណើតវិញ។

- ថ្ងៃទី១៤ ខែ សីហាឆ្នាំ ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំស្តីពីការរៀបចំ វេទិកាវេទិកាអន្តរៈសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី២ នៅសាលអគ្គលេខាធិការដ្ឋាន គជបជ ដែលដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង **ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម

សាវ៉ាយ ធុន រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា (តំណាងសាសនាព្រះពុទ្ធ)។ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន គ.ជ.ប.ជ តំណាងអង្គការ Caritas Cambodia តំណាងសាសនាកាតូលិកកម្ពុជា តំណាងសាសនាឥស្លាមកម្ពុជា។

- ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានដឹកនាំកិច្ចប្រជុំក្រុមទី២ ដែលត្រៀមរៀបចំកម្មវិធី អន្តរសាសនាថ្នាក់ជាតិ លើកទី២ ដោយមានការចូលរួមពីសមាសភាពសរុប១៣រូប ស្រី០៤រូប នៅបន្ទប់ប្រជុំការិយាល័យលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍។

- ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** និង វរសេនីយ៍ឯក លោក អ៊ិន មាន បានចូលរួមកិច្ចប្រជុំពិភាក្សាបន្តលើការងាររៀបចំ វេទិកា អន្តរសាសនា ថ្នាក់ជាតិនៅកម្ពុជាលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយបានដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ចាន់ណារ៉ុ** អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ឯក**ឧត្តមនាយឧត្តមសេនីយ អគ្គលេខាធិការ** និងមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ មកពីស្ថាប័នមួយចំនួនដូចជា៖ ក្រសួងធម្មការ និងសាសនា, ក្រសួងមហាផ្ទៃ, អង្គការការីតាស, កាតូលិក, ព្រះសីហនុរាជ, ដំណឹងល្អ, លេខាធិការដ្ឋានគណៈសង្ឃនាយក។

- ថ្ងៃទី ២១ ដល់ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំនៅទីក្រុងគន់មិញ ខេត្តយន់ណាន ប្រទេសចិន ដែល **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ជាប្រធានប្រតិភូ។ ក្នុងនោះដែរយើងទទួលបានលទ្ធផលប្រសើរ ព្រមទាំងបានស្វែងរកនិតិវិធីសហការល្អ ដើម្បីពន្លឿនការងារជួយជនរងគ្រោះ និងបង្ក្រាបជនល្មើសក្នុងបទល្មើសជួញដូរមនុស្ស។

- ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** លោកវរសេនីយ៍ឯក អ៊ិន មាន និងលោកអនុសេនីយ៍ត្រី ហុក ដារី បានចុះមកសាកសួរសុខទុក្ខ រំលែកទុក្ខ និងសាកសួរព័ត៌មានផ្តល់យោបល់ពីនិតិវិធី ដល់ឪពុកម្តាយជនរងគ្រោះនៅឃុំ ខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ ក្រោយពីបានពិភាក្សាជាមួយ **ឯកឧត្តម ឧត្តមសេនីយឯក ជីវ ផល្លី** ព្រមទាំងបានធ្វើការទំនាក់ទំនង ជាមួយ **លោកជំទាវ ប៉ាល់ យឿន** អភិបាលខេត្តរងខេត្ត កំពង់ឆ្នាំង និងការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តកំពង់ឆ្នាំង។ ករណីនោះកាលពីថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៨ លោកជំទាវបានទទួលព័ត៌មានពីបណ្តាញសង្គមហ្វេសបុក អំពីករណីប្រទះឃើញឆ្អឹងមនុស្សដែលប៉ូលីស តៃវ៉ាន់បានកំណត់អត្តសញ្ញាណថាជាជនជាតិខ្មែរ ដែលត្រូវប្តី សំលាប់កាលពី (តៃវ៉ាន់)២ឆ្នាំមុន។ ដំណឹងបឋមស្ត្រីនេះមានកូនស្រី អាយុ ៨ឆ្នាំ ដែលត្រូវបានអាជ្ញាធរ តៃវ៉ាន់រក្សាទុកនៅ មណ្ឌលកុមារកំព្រា ដោយគ្មានសាច់ញាតិរក្សាដោយសារ ឪពុកត្រូវបានចាប់ខ្លួន។

- ថ្ងៃ២៨ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីអំពីការប្រជុំពិភាក្សាបន្ត (បញ្ចប់) លើការងាររៀបចំ វេទិកា អន្តរសាសនាថ្នាក់ជាតិនៅកម្ពុជាលើកទី ២ ដែលនឹងប្រព្រឹត្តិទៅ នៅ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំនេះបានដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ និង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ **ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ និងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាននៃ គ.ជ.ប.ជ ឯកឧត្តម អស់លោក លោកស្រី តំណាងមកពី ក្រសួង ស្ថាប័ន មួយចំនួនដូចជា: ក្រសួងធម្មការ

និងសាសនា ក្រុមពិធីការ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ អង្គការការីតាស ប្រចាំអាស៊ី និងកម្ពុជា គ្រិស្ទបរិស័ទដំណឹងល្អ គ្រិស្ទបរិស័ទកាតូលិក។

- ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដែលដឹកនាំដោយ **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ ដែលក្នុងនោះដែរបានសហការជាមួយ អង្គការ ការីតាស ប្រចាំកម្ពុជា បានរៀបចំធ្វើ វេទិកា អន្តរសាសនាថ្នាក់ជាតិ លើកទី២ នៅកម្ពុជា ពិធី សូត្រ ធម៌ អធិដ្ឋាន និង បញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង បញ្ចប់ ទាសភាពសម័យទំនើបបានធ្វើឡើង នៅមជ្ឈមណ្ឌល និង ពិព័រណ៍កោះពេជ្រ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។ ក្រៅពីផ្នែក សាសនា ក៏មានអង្គការដៃគូ អង្គការ ការីតាសកម្ពុជា បានគៀងគរ អង្គការដៃគូដទៃទៀត ដែលមាន ឆន្ទៈធ្វើឲ្យមាន ព្រឹត្តិការណ៍នេះឡើង ហើយមានការចូលរួម ពីសាសនិក នៃសាសនា៤ធំៗ គឺ ព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រីស្ទសាសនា កាតូលិក និង គ្រីស្ទបរិស័ទ ដំណឹងល្អ។

**III. ទិសដៅអនុវត្តបន្ត**

- តាមដានទៅលើសេចក្តីពព្រាង អនុស្សរណៈ រវាង គ.ជ.ប.ជ និងអង្គការចាប់ដៃ ទៅលើការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យបច្ចុប្បន្នភាពរបស់អង្គការដៃគូអភិវឌ្ឍន៍។
- បង្កើតទម្រង់ពង្រាងដើម្បីដកស្រង់ព័ត៌មានអំពីអង្គការដៃគូអភិវឌ្ឍន៍ ដោយសហការជាមួយនិងអង្គការចាប់ដៃ ដើម្បីបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ Database។
- រៀបចំកិច្ចប្រជុំបន្តជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងអង្គការដៃគូពាក់ព័ន្ធ ដើម្បីពិភាក្សារៀបចំបង្កើតឲ្យមានវីដេអូអប់រំខ្លី ដើម្បីផ្សព្វផ្សាយដល់សហគមន៍ ក្នុងការបង្ការទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ឆ្លងដែនដែលមិនស្របច្បាប់។
- រៀបចំ Resource Database នៅលើវិបសាយ និង Mobile App ដើម្បីត្រៀមពិភាក្សាជាមួយអង្គការលើផែនការប្រមូលទិន្នន័យ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**ប្រធានស្តីទី**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**

បានឃើញ និងគោរពជូន

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ**

មេត្តាពិនិត្យ និងសម្រេចដោយក្តីគោរព ។

ថ្ងៃ.............................. ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី.............ខែកញ្ញា ឆ្នាំ២០១៨

**អគ្គលេខាធិការរង**